ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី **នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ៣៣៨ **តុលាការកំពូល**

ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៣

សាលដីកា បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ២៨ ខែមិថុនា

លេខ : ១២៨ ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៤ ១- ឯកឧត្តម **ឃឹម ប៉ុណ្ណ** ជាប្រធាន

៣- លោក ជីវ កេង ជាចៅក្រម

២- លោក ស៊ិន ឌីម ជាចៅក្រម

៦- លោក សោម សិរីវឌ្ឍ ជាចៅក្រម

៥- លោក ប៉ែន សាវឿន ជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

កញ្ញា ហុក សុខធុល

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ៦០"ង" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២២០ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ របស់សាលាឧទ្ធរណ៍ រវាង :

- ដើមចោទឈ្មោះខូយ ឆាយ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ មុខរបរផលិតស្រា ទីលំនៅសព្វថ្ងៃភូមិព្រៃល្វា ឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។

- ចុងចម្លើយឈ្មោះឡូវ ណៃ (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥១ឆ្នាំ មុខរបរមេផ្ទះ ទីលំនៅផ្ទះលេខ៩៨AE$_0$ ផ្លូវលេខ២៥៨ សង្កាត់ទួលស្វាយព្រៃ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។

<u>កម្មវត្ថុ</u> : ប្តឹងសុំបដិសេធកិច្ចសន្យា ។

- បានឃើញបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៦០"ង" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣៣៨ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះខូយ ឆាយ ប្តឹងសុំបដិសេធកិច្ចសន្យាពីឈ្មោះឡូវ ណៃ ដោយសំអាងហេតុថា កាលពីឆ្នាំ១៩៩៧ ខ្លួនបានទៅចងការប្រាក់ចំនួន១៣.០០០ដុល្លា ពីឈ្មោះឡូវ ណៃ សន្យាអោយការប្រាក់១ខែ៣៩០ដុល្លា ហើយចងការនេះខ្លួនបានបង់សងរហូតដល់ឆ្នាំ១៩៩៩ ខ្លួនបានសងប្រាក់ចំនួន៨.០០០ដុល្លា នៅខ្វះចំនួន៥.០០០ដុល្លា ទៀត ហើយប្រាក់ដែលនៅខ្វះខ្លួនបានយកប័ណ្ណសំគាល់កម្មសិទ្ធិទីលំនៅដ្ឋាន ដាក់តំកល់ទុកអោយម្ចាស់បំណុល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៧៣"ក" ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០០របស់ដើមចោទឈ្មោះខូយ ឆាយ ទុកជាត្រឹមត្រូវតាមទំរង់ តែសំរេចបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-ទទួលស្គាល់ប័ណ្ណកម្មសិទ្ធិកាន់កាប់អចលនៈវត្ថុលេខ ក.ក.០០២០៩៩ របស់អគ្គនាយកសូរិយោដី និងភូមិបាល ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-បង្គាប់អោយឈ្មោះខូយ ឆាយ "ដើមចោទ " ប្រមូលយកទ្រព្យសម្បត្តិទាំងអស់ជារបស់ខ្លួន ដែលរក្សាទុកនៅលើផ្ទះ ដែលជាកម្មសិទ្ធិរបស់"ដើមចោទ" ចេញអោយផុតពីផ្ទះនេះ ក្នុងកំណត់រយៈពេល១០ថ្ងៃ ដោយគិតចាប់តាំងពីថ្ងៃផុតកំណត់ឧទ្ធរណ៍ ។

៤-សំរេចរឹបអូសប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ពីដើមចោទ ដែលបានបង់ទុករួច :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វឹងចំនួន ១.៨០០រៀល
- រង្វាន់ក្រឡាបញ្ជីហិបប្រាក់ ចំនួន ២០០រៀល
- ចំណាយលើអ្នកប្រគល់ដីកាកោះចំនួន ៥.០០០រៀល

កាលបើផុតកំណត់ឧទ្ធរណ៍បង្គាប់អោយដើមចោទឈ្មោះខូយ ឆាយ បង់ពន្ធសមាមាត្រ១% លើតំលៃផ្ទះទំនាស់ គឺ :

- $\frac{1.500.000R \times 1}{100}$ = ១៥.០០០រៀល ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន៨០% គឺ $\frac{1.5000R \times 80}{100}$ = ១២.០០០រៀល និង ប្រាក់រង្វាន់ក្រឡាបញ្ជីចំនួន២០% គឺ $\frac{1.5000R \times 20}{100}$ = ៣.០០០រៀល ។

- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខចុងចំលើយ កំបាំងមុខដើមចោទទុកសិទ្ធិអោយប្តឹងទាស់រយៈពេល១៥ថ្ងៃ គិតចាប់តាំងពីថ្ងៃទទួលដំណឹង និង បន្ថែមរយៈបេលពីរខែទៀតសំរាប់ប្តឹងឧទ្ធរណ៍ ។

បានឃើញបណ្តឹងទាស់ ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០១ របស់ឈ្មោះខូយ ឆាយ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៧៣"ក" ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១២៨"ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងទាស់ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០១ របស់លោកខូយ ឆាយ "ដើមចោទ" ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីកំបាំងមុខលេខ៧៣"ក" ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ ដែលបានសំរេចសេចក្ដីរួចមកហើយនេះ ទុកជាបានការពេញទាំងមូល ។

- សលាក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្ដីទុកសិទ្ធិអោយប្ដឹងឧទ្ធរណ៍កំណត់ពីរខែ គិតចាប់តាំងពីថ្ងៃនេះតទៅ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ១៤ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះខូយ ឆាយ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១២៨"ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសាលដីការដ្ឋប្បវេណីលេខ២០"ង" ចុះថ្ងៃ០៣ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០២ របស់ឈ្មោះខូយ ឆាយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ១២៨"ក" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០០១ របស់តុលាការខេត្តតាកែវ ទុកជាបានការ ។

៣-កាត់យកប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្វឹងចំនួន២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន៥.០០០រៀល និងលើអាជ្ញាធរតុលាការ ចំនួន៥.០០០រៀល សរុប១៣.០០០រៀល ។

៤-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខចុងចំលើយឈ្មោះឡូវ ណៃ កំបាំងមុខដើមចោទឈ្មោះខូយ ឆាយ ។ បើកផ្លូវប្ដឹងតវ៉ាក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្ដឹងទាស់លេខ២១ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ប្ដឹងមិនសុខចិត្តនឹងសាដីការដ្ឋប្បវេណីលេខ២០"ង" ចុះថ្ងៃ០៣ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ៦០"ង"ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងទាស់ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយផ្ទុយនឹងគតិច្បាប់ ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ២០"ង" ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៣ របស់សាលា-ឧទ្ធរណ៍ទុកជាបានការ ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខចុងចំលើយ កំបាំងមុខដើមចោទ តែចាត់ទុកជាចំពោះមុខ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៦០"ង" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ។

- បានឃើញសារណាតប ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៣ របស់ឈ្មោះឡូវ ណៃ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នៅពេលសវនាការថា : សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះពិនិត្យ និង សំរេច ។

- បានស្តាប់អំណានសារណារបស់ឈ្មោះខូយ ឆាយ នៅពេលជំនុំជំរះ ។

- បានស្តាប់ចម្លើយរបស់អ្នកស្រីឡូវ ណៃ (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជំរះថា : ចំពោះសារណារបស់គាត់បានលើកឡើងនេះ គឺពុំត្រឹមត្រូវទេ តាមពិតដីនេះគាត់បានលក់មកអោយខ្លួននៅចំពោះមុខរដ្ឋអំណាច ក្នុងតំលៃ៥.០០០ដុល្លា ដោយមានកិច្ចសន្យាត្រឹមត្រូវ ។ តែក្រោយមកពេលខ្លួនដាក់ផ្លាកលក់ គាត់បានជំទាស់ហើយប្តឹងទៅតុលាការខេត្ត នៅតុលាការខេត្តគាត់បានសុំទិញដីនេះវិញ ក្នុងតំលៃ៥.៨០០ដុល្លា ហើយសន្យាថា ប្រគល់លុយអោយខ្លួនក្នុងថ្ងៃទី៣០ ខែកុម្ភៈ ឆ្នាំ២០០០ តែគាត់មិនបានគោរពតាមការសន្យានេះទេ គឺគាត់បានប្តឹងបន្តមកតុលាការថ្នាក់លើរហូតមកនេះ ។ ចំពោះរឿងលុយជំពាក់១៣.០០០ដុល្លានេះ គឺបានទូទាត់គ្នារួចរាល់អស់ហើយ ហើយកិច្ចសន្យាខ្ចីលុយនោះ ក៏បាត់អស់ដែរ ។ ចំពោះកិច្ចសន្យាដាក់លុយមួយលានប្រាំសែនរៀលនេះ ជាបច្ចេកទេសរបស់ស្មៀនយាជី ចំណែករូបខ្លួនគឺបានប្រគល់លុយ៥.០០០$ ក្នុងការទិញដីនេះ នៅចំពោះមុខរដ្ឋអំណាចភូមិឃុំ ដីនេះមានទំហំ២០អា ២៤ស.អា ខ្លួនបានធ្វើរបងជុំវិញ និង មានប្លង់ត្រឹមត្រូវ ។ ខ្លួនសូមអោយតុលាការតំកល់សាលដីកាសាលាឧទ្ធរណ៍ទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់សារណារបស់ដើមចោទ និង ចម្លើយរបស់ចុងចម្លើយ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខ២៨៥ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា ការលើឡើងក្នុងសារណា ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣របស់ដើមចោទ ដែលអះអាងថា ខ្លួនបានខ្ចីប្រាក់ពីចុងចំលើយចំនួន១៣.០០០ដុល្លាអាមេរិក និងបានសន្យាឱ្យកំរៃការប្រាក់៣% ក្នុង១ខែ ដោយបានដាក់ប័ណ្ណសំគាល់សិទ្ធិជាសំអាងលេខ$F_H$ 0273 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩២ ដែលមានទំហំដី ២០អា ២៨ស.អ កន្លងមកខ្លួនបានសងប្រាក់៨.០០០ដុល្លា ហើយនៅជំពាក់៥.០០០ដុល្លា ខ្លួនបានសន្យាថាលក់ផ្ទះ និង ដី ឬ លក់ក្រុមហ៊ុនស្រាក្បាលពោធិ ដាច់ដោយ ភាគហ៊ុនជួយចេញសងពាក់កណ្តាលនោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះថា : ដើមចោទបានផ្ទេរសិទ្ធដី និង ផ្ទះទំនាស់ឱ្យចុងចម្លើយរួចហើយ តាមលិខិតផ្ទេរសិទ្ធិ ១៤-០២-២០០០ ហើយតាមកិច្ចសន្យា ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០០ ដើមចោទបានធ្វើការលក់ផ្តាច់ អោយទៅចុងចំលើយនូវអចលនវត្ថុ ដូចខាងលើនេះទៅឱ្យ ចុងចំលើយដោយមានសាក្សីឈ្មោះឆាយ ទ្រី . ជាវ ហ៊ុយ និង ដើមចោទខ្លួនឯងផ្តិតមេដៃផងដែរ នៅចំពោះមុខមេឃុំព្រៃល្វា ក្រោយមកអចលនវត្ថុផ្ទះ ដី នេះ ត្រូវបានអគ្គនាយកដ្ឋានសូរិយោដី បានផ្ទេរសិទ្ធអចនវត្ថុលេខ តក-០០២០៩៩ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០០ ទៅអោយឈ្មោះឡូវ ណៃ រួចហើយ ។

- យល់ឃើញថា ការដែលដើមចោទលើកឡើងថា ខ្លួនសុំបដិសេធកិច្ចសន្យា ព្រោះកាលពីដើមឆ្នាំ ១៩៩៧ ខ្លួនបានចង់ការប្រាក់ពីចុងចំលើយចំនួន១៣.០០០ដុល្លា ខ្លួនបានសងបាន៨.០០០ដុល្លា ហើយនៅជំពាក់ចំនួន៥.០០០ដុល្លាទៀត ប្រាក់នេះគឺជំពាក់ពីសមាជិកក្រុមហ៊ុនស្រាក្បាលពោធិ ដូច្នេះខ្លួនសុំភាគីក្រុម-ហ៊ុនជួយសងជាមួយខ្លួន ការអះអាងនេះពុំមានភស្តុតាងណាបញ្ជាក់ថា ក្រុមហ៊ុនស្រាក្បាលពោធិបានរួមជំពាក់ប្រាក់ចុងចំលើយទេ ។

- យល់ឃើញថា ការដែលដើមចោទលើកឡើងថា អចលនវត្ថុផ្ទះ និង ដី ជាទ្រព្យសម្បត្តិរួមប្តីប្រពន្ធ ដូចនេះការលក់ដូរផ្តាច់របស់ខ្លួន ដែលមិនមានការឯកភាពពីប្រពន្ធកូន គឺជាការពុំត្រឹមត្រូវ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា : ខ្លួនជាប្តី និង ជាឪពុក ពេលប្រពន្ធស្លាប់ទៅ ទ្រព្យនេះត្រូវធ្លាក់មកលើខ្លួនជាអ្នកគ្រប់គ្រង និង មានសិទ្ធិចាត់ចែងបានជាដរាប ព្រោះទ្រព្យសម្បត្តិនេះឪពុកគាត់មិនទាន់ចែកជាមរតកឱ្យកូនណាមួយនៅឡើយ ដែលញុំងឱ្យកូនមានសិទ្ធិប្តឹងតវ៉ាបានក្នុងការលក់ដូរនេះ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៦០"ង" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ហើយ ។

## ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តីចំពោះមុខចុងចម្លើយ កំបាំងមុខដើមចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ២៨៥ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះខូយ ឆាយ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៦០"ង" ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលចុងចំលើយបានបង់ គឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្នឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់
- ចំណាយលើការប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល
- បង្គាប់អោយដើមចោទសងប្រាក់១៩.០០០រៀល នេះទៅចុងចំលើយវិញ ។
- បង្គាប់អោយដើមចោទ បង់ពន្ធសមាមាត្រតាមការកំណត់របស់តុលាការខេត្តតាកែវ ។

៤- សាលដីកានេះ ជំនុំជំរះនាសវនាការជាសាធារណៈនៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៤ និង ប្រកាសនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៤ ។